ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :..............៣០០..............ក.ប/ប្រ.ក.ក.ប.ក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាឆ្លាក់ងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

សហជីពអាចស្នើសុំឲ្យនិយោជកកាត់ប្រាក់ភាគទានពីសមាជិករបស់ខ្លួនបាន លុះត្រាតែសហជីពនោះបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ស្តីពីសហជីព។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ២ .-**

បន្ទាប់ពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសាមី និងត្រូវតែផ្ទេរប្រាក់ភាគទាននោះចូលទៅក្នុងគណនីធនាគាររបស់សហជីពដែលកម្មករនិយោជិតនោះជាសមាជិក។ ត្រូវបានហាមឃាត់មិនឲ្យនិយោជកបង់ប្រាក់ភាគទាននេះជំនួសកម្មករនិយោជិត។

កម្មករនិយោជិតដែលបានអនុញ្ញាតជាលាយលក្ខណ៍អក្សរឲ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនសម្រាប់បង់ភាគទានសហជីពដែលខ្លួនជាសមាជិកនោះ មានសិទ្ធិបដិសេធវិញបានគ្រប់ពេលវេលា។

**ប្រការ៣ .-**

ការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសម្រាប់បង់ភាគទានសហជីពដោយនិយោជក ត្រូវធ្វើឡើងទៅតាមចំនួនប្រាក់ភាគទាន និងបែបបទនៃការបង់ប្រាក់ភាគទានប្រចាំខែ ដែលត្រូវបានកំណត់ជាមុននៅក្នុងលក្ខន្តិកៈរបស់សហជីពដែលកម្មករនិយោជិតសាមីជាសមាជិក។

**ប្រការ៤ .-**

កាលបរិច្ឆេទនៃការកាត់ប្រាក់ឈ្នួលសម្រាប់បង់ជាភាគទានសហជីព ត្រូវកំណត់ឡើងឲ្យដូចគ្នានឹងកាលបរិច្ឆេទនៃថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតសាមី។

សហជីពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់និយោជក ឲ្យបានយ៉ាងតិច ១០(ដប់)ថ្ងៃ មុនការចាប់ផ្តើមកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព អំពីចំនួនប្រាក់ភាគទានសហជីពដែលនឹងត្រូវកាត់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិករបស់ខ្លួន។ សហជីពត្រូវភ្ជាប់មកជាមួយនូវលិខិតយល់ព្រមឲ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព ដែលមានចុះកាលបរិច្ឆេទនិងហត្ថលេខាឬស្នាមម្រាមដៃរបស់កម្មករនិយោជិតសាមី។

សហជីពមានកាតព្វកិច្ចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅនិយោជកជាមុន ស្របតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី២នៃប្រការនេះ ក្នុងករណីដែលមានការកែប្រែថ្មីពាក់ព័ន្ធនឹងការកាត់ប្រាក់ភាគទានជាអាទិ៍ ចំនួនប្រាក់ភាគទាន ឬលេខគណនីធនាគាររបស់សហជីព ឬចំនួនសមាជិកសហជីព ឬនៅពេលកម្មករនិយោជិតណាមួយដកខ្លួនចេញពីសហជីពរបស់ខ្លួន។

**ប្រការ៥ .-**

កម្មករនិយោជិតអាចបដិសេធវិញបានគ្រប់ពេលវេលាចំពោះការកាត់ប្រាក់ឈ្នួលរបស់ខ្លួនសម្រាប់បង់ភាគទានសហជីព ដោយត្រូវធ្វើលិខិតបដិសេធជូនសហជីពដែលខ្លួនជាសមាជិកចំនួន ០១(មួយ)ច្បាប់ឲ្យបានយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃបើកប្រាក់ឈ្នួល។ បន្ទាប់ពីទទួលបានលិខិតបដិសេធ សហជីពសាមីត្រូវចម្លងលិខិតបដិសេធនោះជូននិយោជកឲ្យបានយ៉ាងតិច ០៥(ប្រាំ)ថ្ងៃ មុនថ្ងៃបើកប្រាក់ឈ្នួល។

សហជីពត្រូវសម្រួល និងផ្តល់ទម្រង់លិខិតបដិសេធខាងលើនេះ ជូនកម្មករនិយោជិត។

**ប្រការ៦ .-**

ក្នុងករណីដែលកម្មករនិយោជិតដកខ្លួនចេញពីសហជីពរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហជីព និយោជកត្រូវបញ្ឈប់ការកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានទៅសហជីពដែលកម្មករនិយោជិតសាមីដកខ្លួនចេញ។

**ប្រការ៧ .-**

សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិផ្តាច់មុខក្នុងការចរចាដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវការកំណត់តម្លៃសេវាភ្នាក់ងារសមរម្យឯកភាពមួយដែលមិនលើសប្រាក់ភាគទានប្រចាំខែរបស់សមាជិកខ្លួន។ តម្លៃសេវាភ្នាក់ងារនេះត្រូវបង់តែម្តងគត់។

ប្រសិនបើសហជីពមូលដ្ឋានណាមួយបានគាំទ្រសហជីពមូលដ្ឋានមួយផ្សេងទៀត ឲ្យទទួលបានភាពជាតំណាងបំផុត ដូចមានចែងនៅក្នុងចំនុច "គ" ត្រេទី២ នៃមាត្រា៥៤ នៃច្បាប់ស្តីពីសហជីព សមាជិកនៃសហជីពនោះមិនតម្រូវឲ្យបង់សេវាភ្នាក់ងារ ជូនសហជីពដែលទទួលបានភាពជាតំណាងបំផុតនោះទេ។

**ប្រការ៨ .-**

និយោជកត្រូវរក្សាទុកកំណត់ត្រាទាំងឡាយ នៅពេលណាដែលខ្លួនបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិតសម្រាប់បង់ជាភាគទានសហជីពឬប្រាក់សេវាភ្នាក់ងារ។ កំណត់ត្រាទាំងនេះត្រូវដាក់បញ្ចូលនូវៈ

- កាលបរិច្ឆេទនៃការយល់ព្រមរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពសាមី
- កាលបរិច្ឆេទបង់ប្រាក់សេវាភ្នាក់ងារ
- កាលបរិច្ឆេទនិងចំនួនទឹកប្រាក់ភាគទានដែលបានកាត់សម្រាប់កម្មករនិយោជិតម្នាក់ៗ និង
- កាលបរិច្ឆេទនិងចំនួនទឹកប្រាក់ដែលបានផ្ទេរទៅឲ្យសហជីពពាក់ព័ន្ធ។

និយោជកត្រូវរក្សាទុកកំណត់ត្រាទាំងនេះឲ្យបានគង់ក្នុងរយៈពេល ០៣(បី)ឆ្នាំ និងត្រូវចម្លងជូនសហជីព ប្រសិនបើមានការស្នើសុំពីសហជីពសាមី។

**ប្រការ៩ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានអង្គភាពក្រោមឱវាទនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៥រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៩
  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ